ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ:៦២០/០១-០៧-២០១៤
សាលដីកា
លេខ២៦ក្រIVសស/២៨-១០-២០១៤

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៤ បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៤ ដោយមានសមាសភាពដូចតទៅ:

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោក [redacted] ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក សរ យសថាវរៈ

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោកស្រី ខ្លែន កិន្នរី

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍រឿងព្រហ្មទណ្ឌលេខ៦២០ ចុះថ្ងៃទី០១-០៧-២០១៤ ដែលមាន៖

១-ឈ្មោះ [redacted] រដ្ឋា ភេទប្រុស អាយុ៥៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកអង្គការការពារសត្វព្រៃ ទីលំនៅកំណើតភូមិ [redacted] ទីលំនៅសព្វថ្ងៃ [redacted] ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធ ឈ្មោះ [redacted] មានកូន០១នាក់ ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី ១៣-១២-២០១៣។(ដើមបណ្តឹងឧទ្ធរណ៍)

២-ឈ្មោះ [redacted] ចំរើន ភេទប្រុស អាយុ៥២ឆ្នាំ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកអង្គការការពារសត្វព្រៃ កើតនៅ [redacted] ទីលំនៅសព្វថ្ងៃភូមិ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន០៧នាក់ ទោសពីមុនគ្មាន ។

១៥៩

ជាប់ចោទពីបទៈកំហែងយក ប្រព្រឹត្តនៅភូមិជ័យថ្មី ឃុំព្រៃក្មេង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ កាល ពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣។

-បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៦៣,មាត្រា៣៦៤ នៃក្រមព្រហ្មទណ្ឌ។

**<u>រឿងហេតុមានដូចតទៅ</u>**

នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ វេលាម៉ោង៦.២០នាទីព្រឹក នៅភូមិជ័យថ្មី ឃុំព្រៃក្មេង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ មានករណីកំហែងយកមួយបានកើតឡើងដែលបង្កដោយជនសង្ស័យ ឈ្មោះ [redacted] រដ្ឋា និងឈ្មោះ [redacted] ចំរើន ដោយឈ្មោះទាំងពីរនាក់នេះ បានធ្វើសកម្មភាពស្ទាក់រថយន្ត និង រ៉ឺម៉កដឹកឈើដើម្បីទារយកប្រាក់ ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៦៦"ក"ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ដែលមានខ្លឹមសារសេចក្តីសំរេចដូចតទៅៈ

១-ផ្តន្ទាទោសលើឈ្មោះ[redacted]រដ្ឋា ឈ្មោះក្រៅគ្មាន ភេទប្រុស អាយុ៥៦ឆ្នាំ និងឈ្មោះ[redacted] ចំរើន ឈ្មោះក្រៅគ្មាន ភេទប្រុស អាយុ៤២ឆ្នាំ (មានសាវតាជាតិ) ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗចំនួន០២ឆ្នាំ(ពីរឆ្នាំ) តែទោសនេះ ត្រូវអនុវត្តក្នុងពន្ធនាគារក្នុងម្នាក់ៗចំនួន០៧ខែ(ប្រាំពីរខែ) គិតពីថ្ងៃឃុំខ្លួននៅថ្ងៃ ទី១៣ ខែធ្នូ ឆ្នាំ២០១៣ ទោសសល់ពីនេះត្រូវព្យួរធម្មតានិងពិន័យជាប្រាក់រួមគ្នាចំនួន៤.០០០.០០០រៀល(បួនលានរៀល)សំរាប់បង់ចូលថវិការដ្ឋ។នៅពេលសាលក្រមចូលជាស្ថាពរ។

ពីបទៈកំហែងយក កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ប្រព្រឹត្តនៅភូមិជ័យថ្មី ឃុំព្រៃក្មេង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

-បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៦៤,១០៤ និង១០៨ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

-ក្នុងករណីទណ្ឌិតទាំងពីរនាក់រឹងរូសមិនព្រមបង់ត្រូវអនុវត្តការបង្ខំដល់រូបកាយតាមច្បាប់កំណត់(មាត្រា៥២៣.៥៣០នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

២-វត្ថុតាងមានៈរថយន្តម៉ាកកាមរីពណ៌ស ស៊េរី ១៩៨៥ ពាក់ស្លាកលេខ ឃ.០១១៤ភ.ព២ មួយគ្រឿង កង់សារគូរមួយគ្រាប់ កាតាបស្ពាយ០២ពណ៌ខ្មៅ (ធំមួយ-តូចមួយ) ទូរសព្ទដៃម៉ាក ណូគារមួយគ្រឿង និងឯកសារសៀវភៅមួយចំនួនត្រូវប្រគល់ឲ្យម្ចាស់យកទៅប្រើប្រាស់វិញ នៅពេលសាលក្រមចូលជាស្ថាពរ បន្ទាប់ពីបង់ប្រាក់ពិន័យរួច។

៣-សាលក្រមនេះជំនុំជំរះនិងប្រកាសជាសាធារណៈនៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤ ចំពោះមុខជនជាប់ចោទ។

បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២៩ ចុះថ្ងៃទី ២៣-០៥-២០១៤ របស់លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ស្ពឺ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ-

១៦០

៦៦"ក" ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ត្រង់ចំណុចទី១ សេចក្តីសម្រេច នៃសាលក្រម។

បានឃើញរបាយការណ៍ចុះថ្ងៃទី ០២-០៩-២០១៤ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍

បានឃើញសេចក្តីសន្និដ្ឋានចុះថ្ងៃទី ១៣-១០-២០១៤ របស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា , [redacted] ចំរើន (អវត្តមាន),

ប្រធានក្រុមប្រឹក្សាៈអានរបាយការណ៍ បញ្ជាក់អង្គហេតុនៃរឿង

តុលាការ ៖ អានចម្លើយ ជនជាប់ចោទ , អានចម្លើយសាក្សី

តំណាងមហាអយ្យការផ្តល់សេចក្តីសន្និដ្ឋានៈ

បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា បើតាមចំណាងឯកឧត្តមអគ្គព្រះរាជអាជ្ញារងថា បណ្តឹងនេះពុំបានបញ្ជាក់ពីសំណើរបស់ខ្លួនទេ ឬមួយទណ្ឌកម្មស្រាលពេកឬធ្ងន់ពេក តែអាចកំណត់បានថា សុំឲ្យសាលាឧទ្ធរណ៍តម្លើងទណ្ឌកម្មអំពីទោសដាក់ពន្ធនាគារ សុំក្រុមប្រឹក្សាសម្រេចតាមច្បាប់។

-ក្រោយពីបានស្តាប់ការអានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ការអានចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាល្អិតល្អន់ត្រឹមត្រូវតាមច្បាប់ហើយ។

**<u>យល់ឃើញថា</u>**

១-ពាក្យបណ្តឹងឧទ្ធរណ៍លេខ២៩ចុះថ្ងៃទី២៣ខែឧសភាឆ្នាំ២០១៤ របស់លោកទី មុនីន្ទ ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ស្ពឺ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ៦៦"ក" ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តកំពង់ស្ពឺត្រង់ចំណុចទី១ នៃសេចក្តីសម្រេច ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍អាចលើកយកមកជំនុំជម្រះបាន តាមមាត្រា៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-តាមស្តាប់អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] រដ្ឋា បានឆ្លើយបដិសេធន៍ថា ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ខ្លួនមានតួនាទីបុគ្គលិកអង្គការការពារព្រៃឈើនិងសត្វព្រៃបរិស្ថានភ្នំឱរ៉ាល់។ ថ្ងៃទី១១-១២-២០១៣ ខ្លួនបានហៅម៉ូតូដឹកឈើឥតច្បាប់ ដើម្បីសាកសួរអំពីឈើនោះដឹកមកពីណាមក អ្នកដឹកឈើសួរខ្លួនវិញធ្វើការនៅឯណា ខ្លួនថា ជាបុគ្គលិកអង្គការការពារព្រៃឈើ សត្វព្រៃ បរិស្ថានភ្នំឱរ៉ាល់ ពេលនោះ អ្នកដឹកឈើគេឲ្យលុយខ្លួន៥.០០០រៀល ។ កន្លងមកខ្លួនតែងហៅម៉ូតូ និង គោយន្តដឹកឈើ ប្រហែល៦ដងហើយគេឲ្យលុយ៧០.០០០រៀលប៉ុណ្ណោះ ។ ការឲ្យលុយរបស់អ្នកដឹកឈើគឺឲ្យដោយមនោសញ្ចេតនា ខ្លួនពុំបានគំរាមកំហែងអ្នកដំណើរឡើយ ។ ពេលហៅអ្នកដឹកឈើឲ្យឈប់ បើគេសួរខ្លួនប្រាប់ពីមុខងាររបស់ខ្លួន។

៣-តាមស្តាប់អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] ចំរើន បានឆ្លើយបដិសេធន៍ថា ខ្លួនពុំដែលហៅម៉ូតូឬគោយន្តដឹកឈើដើម្បីទារលុយទេ ថ្ងៃកើតហេតុខ្លួនដឹកឪពុកក្មេកឈ្មោះ [redacted] រដ្ឋា ទៅភូមិជ័យថ្មី ឪពុកក្មេកខ្លួនបានរាដៃឲ្យម៉ូតូឬគោយន្តឈប់ ខ្លួនក៏បានឈប់ឡាន ឪពុកក្មេកក៏ចុះទៅសួរ ខ្លួនពុំដឹងគាត់និយាយអំពីអ្វីទេ ការហៅម៉ូតូឬគោយន្តមានពីរដង ឪពុកក្មេកពុំបានបបួលខ្លួនកាត់ម៉ូតូឬគោយន្តដើម្បីយក

លុយដូចការចោទប្រកាន់ទេ ហើយការនិយាយជាមួយរ៉ឺម៉កឬគោយន្តក៏ឪពុកក្មេកពុំបានប្រាប់ដែរ ព្រោះខ្លួននៅក្នុងឡាន។

៤-តាមស្តាប់អំណានចម្លើយឲ្យការណ៍របស់សាក្សីឈ្មោះ ទេព សួង,សុក ផននិងណឹម ម៉ៅបានឆ្លើយប្រហាក់ប្រហែលគ្នាថា កន្លងមកឈ្មោះ [redacted] រដ្ឋា និងបក្សពួកពីរនាក់ទៀតតែងតែជិះរថយន្តកាំម៉ារីពណ៌សដេញចាប់ប្រជាពលរដ្ឋដឹកឈើតាមរ៉ឺម៉កឬគោយន្ត ដើម្បីទារប្រាក់ជាញឹកញាប់,សាក្សីឈ្មោះ ទេព សួង ថា ខ្លួនសួរជនជាប់ចោទថាមកពីណា គេថា ២៤ខេត្ត ក្រុង ទើបមកពីខេត្តកោះកុង ។ កន្លងមកក្រុមនេះធ្លាប់ចាប់ឈើកូនខ្លួនទារលុយ៤០.០០០រៀលនិងចាប់គោយន្ត៣គ្រឿង ដឹកឈើដុំហើយបានយកលុយ១គោយន្ត១០០.០០០រៀលសរុប៣០០.០០០រៀល។ថ្ងៃទី១១-១២-២០១៣ ពេលខ្លួនដឹកឈើក៏ឃើញមនុស្សម្នាក់និងរថយន្តនោះចេញមកបញ្ឆាំងពិលដាក់ខ្លួន តែខ្លួនពុំបានឈប់ទេ លុះដល់ម៉ោង៨ព្រឹកមេឃុំនិងប៉ូលីសមកដល់ចំណុចកើតហេតុក៏ចាប់[redacted]រដ្ឋា និងបក្សពួកដែលឃាត់រ៉ឺម៉កយកលុយ។

៥-ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា [redacted] ចំរើន ពុំសារភាពពីអំពើរបស់ខ្លួនទេ ប៉ុន្តែបានទទួលស្គាល់ថាពិតជាបានជិះរថយន្តដេញតាមរ៉ឺម៉កឬគោយន្តដឹកឈើនិងបានទទួលប្រាក់៥.០០០រៀល ទៅ១០.០០០រៀលប៉ុណ្ណោះ ហើយការដែលអ្នកដឹកឈើឲ្យប្រាក់មកខ្លួនគឺជាការឲ្យដោយមនោសញ្ចេតនា ដោយពួកខ្លួនមិនបានគំរាមកំហែងអ្នកដឹកឈើទេ ចម្លើយដោះសារពុំអាចឲ្យតុលាការជឿបានឡើយ ព្រោះបើតាមចម្លើយសាក្សីទាំងអស់បានបញ្ជាក់ស៊ីសង្វាក់ គ្នាថា ជនជាប់ចោទឈ្មោះ[redacted] រដ្ឋា និងបក្សពួកពិតជាបានជិះរថយន្តម៉ាកកាម៉ារីពណ៌សដេញតាមចាប់ប្រជាពលរដ្ឋដឹកឈើតាមរ៉ឺម៉កដើម្បីទារប្រាក់ជាញឹកញាប់នៅភូមិជ័យថ្មី ឃុំព្រៃក្មេង ស្រុកភ្នំស្រួច ដោយបានអះអាងថា ខ្លួនជាបុគ្គលិកអង្គការការពារព្រៃឈើសត្វព្រៃបរិស្ថានភ្នំឱរ៉ាល់។ ចម្លើយឲ្យការណ៍របស់សាក្សីស៊ីសង្វាក់និងរបាយការណ៍របស់អាជ្ញាធរភូមិ ឃុំនិងអធិការភ្នំស្រួចបានធ្វើរបាយការណ៍លេខ៥០៦ ចុះថ្ងៃទី ១១-១២-២០១៣កាលពីថ្ងៃទី ១១-១២-២០១៣ មានឈ្មោះ [redacted] ឡេងមករាយការណ៍ប្រាប់សមត្ថកិច្ចថា មានមនុស្សប្រុស៣នាក់បានដាក់ប៉ុស្តិ៍ឃាត់ត្រួតពិនិត្យអ្នកបើករ៉ឺម៉កនិងគោយន្តដឹកឈើដើម្បីទារប្រាក់។អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា [redacted] ចំរើន មានធាតុផ្សំគ្រប់គ្រាន់ជាបទកំហែងយកដូចមានបញ្ញត្តិតាមមាត្រា៣៦៣នៃក្រមព្រហ្មទណ្ឌ។ជនជាប់ចោទបានអះអាងថា ខ្លួនមានតួនាទីជាបុគ្គលិកអង្គការការពារព្រៃឈើ សត្វព្រៃ នៅពេលពួកខ្លួនឃើញប្រជាពលរដ្ឋដឹកឈើខុសច្បាប់ហើយពួកខ្លួនពុំបានរាយការណ៍ជូនសមត្ថកិច្ចឬមន្ត្រីជំនាញទេ បែរជាគំរាមអ្នកដឹកឈើថា ខ្លួនជាអ្នកមានសមត្ថកិច្ចលើ២៤ខេត្ត ក្រុង ដើម្បីអោយអ្នកដឹកឈើប្រគល់ប្រាក់មកឲ្យខ្លួនវិញ ។ អំពើរបស់ជនជាប់ចោទធ្វើឡើងជាច្រើនលើកច្រើនសារធ្វើឲ្យប្រជាពលរដ្ឋទទួលរងគ្រោះច្រើននាក់ គប្បីតម្លើងទណ្ឌកម្មទោសដាក់ពន្ធនាគារបន្ថែម ។

៦-សាលក្រមព្រហ្មទណ្ឌលេខ៦៦"ក" ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តកំពង់ស្ពឺ បានធ្វើការស៊ើបសួរនិងលើកយកសំអាងហេតុក្នុងការសម្រេចសេចក្តីមានលក្ខណៈត្រឹមត្រូវរួចហើយគួរសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍តម្កល់ទុកជាបានការ លើកលែងតែការផ្តន្ទាទោសដាក់ពន្ធនាគារលើឈ្មោះ [redacted] រដ្ឋា និង [redacted] ចំរើន ត្រូវកែប្រែតាមការយល់ឃើញដូចខាងលើ ។

៧-សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ សុំឲ្យសាលាឧទ្ធរណ៍ តម្លើងទណ្ឌកម្មអំពីទោសដាក់ពន្ធនាគារធ្វើឡើងត្រឹមត្រូវតាមច្បាប់។

១៦២

## ហេតុដូចនេះទនិច្ឆ័យសេចក្ត

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ២៩ ចុះថ្ងៃទី២៣ខែឧសភាឆ្នាំ២០១៤ របស់លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ស្ពឺ ទុកជាត្រឹមត្រូវតាមច្បាប់ ។

២-តំកល់សាលក្រមព្រហ្មទណ្ឌលេខ៦៦"ក" ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ទុកជាបានការដដែល លើកលែងតែចំណុចទោសអោយឈ្មោះ [redacted] រដ្ឋា និង [redacted] ចំរើន អនុវត្តទោសក្នុងពន្ធនាគារចំនួន០៧ខែ គិតពីថ្ងៃឃុំខ្លួនថ្ងៃទី១៣ ខែ ធ្នូ ឆ្នាំ២០១៣ ត្រូវកែប្រែមកជា"*ទោសត្រូវអនុវត្តក្នុងពន្ធនាគារលើឈ្មោះ [redacted] រដ្ឋា និង [redacted] ចំរើន កំណត់រយៈពេល០១ឆ្នាំ (មួយឆ្នាំ)*"វិញ ហើយទោសសល់ពីនេះព្យួរធម្មតា ចំណុចក្រៅពីនេះរក្សាទុកជាបានការដដែល ។

៣-បន្តការឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៤ កំបាំងមុខជនជាប់ចោទ ទុកសិទ្ធិប្តឹងទាស់និងប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់តំណែងជួយសហការអនុវត្តសាលដីកានេះអោយបានសម្រេចបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

ចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ១២ ខែ មករា ឆ្នាំ២០១៥

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

១៦៣